# ១៦~ រឿង ឪពុកក្មេករើសកូនប្រសា

កាលពីព្រេងនាយមានតាចាស់ម្នាក់ និង ដូនចាស់ម្នាក់នៅស្រុកមួយ ។ តាចាស់យាយចាស់នោះ គាត់មានកូនក្រមុំម្នាក់រូបល្អណាស់ អ្នកណាទៅដណ្ដឹងក៏គាត់មិនព្រមឱ្យ គាត់ថា "អ្នកណាតមមិនជេរម្ដាយគេបាន ទើបគាត់ឱ្យកូនជាប្រពន្ធអ្នកនោះ" ។

ជួនជាថ្ងៃមួយនោះ មានកម្លោះម្នាក់រូបរាងស្អាតបាតចូលទៅដណ្ដឹងកូនគាត់ៗថា "អើអញឲ្យឯងៗកុំព្រួយចិត្ត ប៉ុន្តែឯងត្រូវតមកុំជេរម្ដាយគេហើយទទួលបំរើអញ តាមពាក្យអញបានអញឲ្យឯង បើតមមិនបានអញផ្ដាច់មិនឲ្យឯងទេ អញប្រាប់ឯងមុនឲ្យដឹងក្រោយឯងកុំថា អញកាចណា!" ។

កម្លោះនោះថា "ខ្ញុំបាទតមជេរម្ដាយគេបាន ហើយធ្វើការអ្វីៗបានទាំងអស់ ខ្ញុំបាទទទួលសព្វគ្រប់ប្រការតាមប្រសាសន៍លោកឪពុក" តានោះថា "អើបើឯងតមជេរម្ដាយគេបានមែន ឯងទៅសិនចុះ ព្រឹកឯងមកវិញពីព្រលឹម" ។ កម្លោះនោះក៏លាទៅផ្ទះវិញ ។

ព្រឹកឡើងកម្លោះនោះមកវិញចូលទៅបំរើឪពុកម្ដាយក្មេក តានោះប្រើកូនក្រមុំគាត់ឲ្យរៀបបាយទឹកឲ្យអ្នកកម្លោះនោះស៊ីៗរួចហើយ តានោះប្រាប់ទៅកូនប្រសាថា "កូនទៅចាប់ក្របីទៅភ្ជួរស្រែ ដល់កាលណាថ្មនៅខាងស្រែនោះយំតេវៗ ច្រេចៗ សឹមឯងដោះក្របីលែង" ។ អ្នកកម្លោះទៅចាប់ក្របីមកទឹម ហើយទៅភ្ជួរស្រែតាំងពីព្រលឹមដល់ថ្ងៃត្រង់ក៏ថ្មពុំយំ ក្របីដើរពុំរួចក៏ថ្មចេះតែឈឹង ពុំយំសោះ ។ អ្នកកម្លោះឃ្លានបាយណាស់ទ្រាំពុំបានជេរម្ដាយថា "ម្ដាយអាថ្មនេះ កាលណានឹងយំឡើង" ។ កម្លោះនោះជេរតែប៉ុណ្ណោះ តានោះស្ទុះចេញពីក្រោយថ្មមកថា "ណ្ហើយចុះ ឯងដោះក្របី លែងហើយទៅផ្ទះឯងចុះអញផ្ដាច់កូនហើយ ត្បិតឯងតមជេរម្ដាយមិនបាន" កម្លោះនោះដោះក្របីលែង ហើយទៅផ្ទះវិញ ។

ថ្ងៃក្រោយមក មានកម្លោះម្នាក់ចូលទៅដណ្ដឹងកូនតានោះទៀត គាត់បង្គាប់ដូចកម្លោះមុន តែអ្នកកម្លោះក្រោយគេ មានប្រាជ្ញា គេទៅភ្ជួរស្រែវេចបាយទៅស៊ីផង លុះភ្ជួរដល់ថ្ងៃខ្ពស់ឃ្លានបាយ ក៏បញ្ឈប់ក្របីស៊ីបាយ ភ្ជួរដល់ថ្ងៃជ្រេពីត្រង់ ក៏ថ្មពុំយំ ក្របីអស់ជើងដើរពុំរួច អ្នកកម្លោះនោះកាលណាបើបរក្របីទៅជិតថ្មនោះ ធ្វើជាស្ដីថា "ឱលោកថ្មអើយយំឡើងក្របីដើរពុំរួចទេ អាណិតក្របីផងទៅ ខ្លួនខ្ញុំឥតអីទេ ខ្ញុំមានបាយស៊ីហើយភ្ជួរដល់យប់ក៏បានដែរ អាណិតតែក្របីទៅចុះត្បិតវាជាសត្វ"។ កម្លោះនោះអង្វរដូចម្ដេចក៏ថ្មពុំយំ អ្នកកម្លោះនោះក៏ពុំជេរ ត្បិតវាដឹងថាតានោះនៅពួនក្រោយថ្ម លុះនិយាយអង្វរយូរទៅតានោះមើលមកឃើញក្របីដើរពុំរួចមែនក៏គាត់នឹកអាណិតក្របីគាត់ៗ យំក្រោយថ្មនោះឮតែតេវៗ អ្នកកម្លោះនោះក៏ដោះក្របីឱ្យស៊ីស្មៅ ហើយមកផ្ទះឪពុកក្មេកវិញ។ តានោះក៏ឱ្យកូនគាត់លើកបាយមកឲ្យអ្នកកម្លោះនោះស៊ី។ លុះល្ងាចតានោះប្រាប់ថា "កូនអើយទៅផ្ទះឯងចុះ ព្រឹកសឹមឯងមកវិញ"។ កម្លោះនោះក៏លាទៅផ្ទះ លុះយប់មកលបចាំស្ដាប់នៅក្រោមដំណេកតានោះយកការណ៍ ព្រោះគាត់និយាយគិតគូនឹងប្រពន្ធគាត់ទាល់តែដេកលក់។

វេលាយប់ តាចាស់ចូលដេកក៏និយាយនឹងយាយថា "ដូន! អានេះវាតមជេរម្ដាយបាន ដូច្នោះយើងរកឧបាយយ៉ាងណា ? ឱ្យវាខឹងជេរម្ដាយយើងនឹងផ្ដាច់វាទៅ"។ ដូនឆ្លើយថា "ងាយទេបើដូច្នេះ តាឯងចូលក្នុងការុងមួយ ការុងមួយទៀតដាក់អង្ករ ព្រឹកឡើងវាមក ខ្ញុំប្រាប់វាថា "តាទៅកាប់អុសលើភ្នំមុនហើយ" ខ្ញុំឲ្យវាវែកតាឯង និង អង្ករទៅលើភ្នំ បើវាធ្ងន់វាខឹង វាជេរនោះតាឯងនៅក្នុងការុងឮហើយមកវិញផ្ដាច់វាបានដោយងាយ"។ តាយាយគិតគ្នាដូច្នេះហើយក៏ដេកទៅ ឯអ្នកកម្លោះលបស្ដាប់ក្រោមផ្ទះដឹងការហើយ ក៏វិលទៅដេកឯផ្ទះ។ ព្រឹកឡើងអ្នកកម្លោះនោះទៅបំរើម្ដាយក្មេកឪពុកក្មេក ក៏ស្រាប់តែឃើញយាយចាស់ បង្ហាញអំរែកហើយប្រាប់ថា "កូនអើយ ឪឯងទៅកាប់អុសលើភ្នំហើយ គាត់ផ្ដាំថា ឱ្យកូនឯងវែកអង្ករនេះឡើងទៅតាមគាត់ឱ្យឆាប់ ត្បិតគាត់ទៅពីព្រឹកមិនទាន់ហូបបាយ មានតែកូនឯងវែកទៅឆាប់ វានឹងអាលដណ្ដាំបាយឲ្យឪឯងហូប"។ កម្លោះនោះទទួលអំរែកហើយ ក៏វែកទៅតាមជើងភ្នំ ដល់វែកឡើងបន្តិចទៅធ្ងន់ណាស់ក៏វែកចុះមកវិញ ហើយស្ដីថា "ឱ ឪអើយ! ខ្ញុំឃ្លានបាយណាស់ខ្ញុំវែកឡើងជាឆាប់មិនបានទេ វាធ្ងន់ម្លេះ នរណានឹងវែកឡើងទៅវិញរួច បើឪមិនអាណិតគាត់ជេរបន្ទោសដូចម្ដេចក៏ទទួល"។ និយាយហើយ វែកចុះមកវិញ លុះវែកទៅដល់កន្លែងមួយឃើញស្បូវស្ងួតល្អក៏វែកទៅដាក់ឈប់កណ្ដាលស្បូវនោះ ហើយដើរទៅបាត់មួយស្របក់ទើបដើរត្រឡប់មកវិញយកភ្លើងដុតជុំអំរែក លុះភ្លើងឆេះស្បូវជុំវិញ ហើយក្ដៅដល់តាចាស់ដែលនៅក្នុងអំរែកនោះ គាត់ក៏បំរាស់ញ័ររង្គើរទាំងការុងភ័យក្រែងភ្លើងឆេះស្លាប់ប៉ុន្តែចេញមិនរួច។ អ្នកកម្លោះធ្វើជារត់មកពីណាក៏ស្រែកថា "ដើ! នរណាដុតភ្លើងឆេះអំរែកអញអស់ធ្វើដូចម្ដេចអញនឹងចូលទៅបាន ភ្លើងឆេះជុំវិញចូលមិនរួចទេ" ថាហើយស្រែកឈររនៅក្រៅ លុះភ្លើងឆេះដល់ការុងក្ដៅតាចាស់ណាស់ទើបស្ទុះចូលទៅអូសអំរែកចេញពីភ្លើង រួចហើយភ្លើងឆេះដាច់ខ្សែការុងរលាកតាចាស់បំរះញ័រៗ ទើបអ្នកកម្លោះស្រាយការុងចេញឃើញតាឪពុកក្មេករលាកភ្លើងឆេះទាំងសក់ក្បាលផងក៏ជម្រាបថា "ដើលោកឪ! ម្ដេចក៏មិនប្រាប់កូន កុំអីភ្លើងឆេះស្លាប់ចោលម៉ែឲ្យនៅមេម៉ាយ"។ តាចាស់ខឹងណាស់តែពុំដឹងជាធ្វើដូចម្ដេច ឡើងដើរតយង៉យមកផ្ទះវិញទ្រមខ្លួនមួយថ្ងៃ ណាមួយដោយវាអូសចេញពីភ្លើងណាមួយរលាកភ្លើង មកដល់ផ្ទះវិញគ្មានស្ដីមួយម៉ាត់ ដល់ផ្ទះហើយប្រាប់កូនប្រសាថា "ទៅផ្ទះចុះព្រឹកសឹមមក"។ ឯកូនប្រសាលាទៅផ្ទះដល់យប់លបពួនក្រោមផ្ទះស្ដាប់ទៀត។

លុះយប់តាចាស់ដូនចាស់ចូលដេកក៏និយាយគិតគ្នាទៀត តាថា "គិតដូចម្ដេចនឹងផ្ដាច់វាបាន ? អានេះមានប្រាជ្ញាណាស់ តែនឹងឲ្យកូនយើងទៅវា វាមិនសមនឹងកូនយើងពីថ្ងៃមិញវាដឹងថា ឯងនៅក្នុងការុង ណាវែកទៅដល់កណ្ដាលផ្លូវ វាថាធ្ងន់ណាស់ តែម្ដាយវាមិនជេរ វារកទីណាមានស្បូវស្ងួត វាវែកអំរែកទៅដាក់កណ្ដាលស្បូវ ហើយវាដើរទៅរកភ្លើងមកដុតជុំវិញ។ ដល់ភ្លើងឆេះវាធ្វើជាស្រែកថា នរណាដុតភ្លើងនេះឆេះអំរែកវាអស់ហើយវាឈរតែស្រែកមិនចូលយកខុកទាល់តែភ្លើងឆេះដល់ក្ដៅ

ទើបបានវារត់ចូលទៅអួសចេញមក អញភ័យណាស់ប៉ុន្តែចេញមិនរួច ព្រោះវាចងមាត់ការុងជាប់ អញរលាកអស់ទាំងខ្លួន ឥឡូវនេះយើងគិតដូចម្តេច នឹងផ្តាច់វាបាន"។ យាយថា "ឥឡូវនេះយើងគិតថា ឲ្យតាឯងធ្វើម្ចាស់ ឱ្យវាធ្វើឆ្កែនាំទៅបណ្តើរអណ្តើក ឱ្យវាវារដូចឆ្កែ បើវារកអណ្តើកមិនបាន ឬវាបោលមិនរួច នោះយើងផ្តាច់វាបាន"។ តាចាស់ថា"អើ! ដូនគិតដូច្នេះត្រូវ ព្រឹកអញធ្វើដូចឯងថា"។ តាយាយគិតគ្នាហើយដេកទៅ។ ឯអ្នកកម្លោះនោះស្តាប់ដឹងអស់ការហើយ វិលទៅផ្ទះវិញដេកដល់មាន់រងាវ ទើបពុនអណ្តើកយកទៅចងទុកក្នុងកម្ពោតស្មៅឯវាល ឯនេះ ឯនោះ ពាសពេញតែវាល ដែលតាចាស់គាត់គិតទៅរកអណ្តើកនោះ ហើយវិលមកផ្ទះដេកធ្វើព្រងើយ។

លុះព្រឹកព្រហាមឡើង ចៅនោះទៅដល់ផ្ទះឪពុកក្មេកម្តាយក្មេកៗក៏ឲ្យកូនក្រមុំគាត់រៀបបាយលើកយកមកឱ្យចៅនោះស៊ី ៗរួចហើយក៏ប្រាប់ថា"កូន! ឥឡូវនេះយើងទៅបណ្តើរអណ្តើក ប៉ុន្តែយើងគ្មានឆ្កែ កូនឯងធ្វើឆ្កែឪធ្វើម្ចាស់ យើងទៅរកក្រែងបានមួយពីរយកមកស៊ី"។ ចៅនោះឆ្លើយបាទ ហើយតាចាស់ពុនបាយសំណុំទឹកបំពង់ដើរចេញពីផ្ទះទៅ។ ចៅនោះក៏បោលជើងបួនតាមក្រោយទៅ ដល់វាលកន្លែងវាចងអណ្តើកនោះ ក៏វាបោលទៅមុនចូលកម្ពោតស្មៅមួយវាកោះងុយៗ។ តាចាស់រត់ទៅដល់វាខាំបានអណ្តើកមួយ ហើយបោលទៅទៀត ខាំបានអណ្តើក៦-៧ ដល់ថ្ងៃត្រង់តាចាស់ឃ្លានពេកណាស់ ក៏អង្គុយគិតស្រាយបាយស៊ី។ ឆ្កែមើលទៅខាងឃើញក្របីមួយហ្វូងក៏បោលទៅដេញខាំក្របី ក្របីបោលចូលស៊ីស្រូវអ្នកស្រុក តាចាស់ឃើញហើយរត់ទៅដេញឆ្កែ ដេញក្របីចេញពីឆ្កែៗបោលមកស៊ីបាយអស់ហើយបោលទៅបាត់។ ឪពុកក្មេកម្ចាស់ឆ្កែវិលមកវិញរកបាយស៊ីគ្មានឆ្កែស៊ីអស់ ខឹងណាស់ដេញវាយពុំទាន់ណាអស់កម្លាំងឃ្លានបាយ ណាផ្លូវឆ្ងាយក៏ខំដើរមកផ្ទះវិញ ទាំងអត់បាយដើរពុំរួច បន្ទោសឆ្កែមិនបានពិតឆ្កែវាចំណាំតែអញហ្នឹង។ ដល់ផ្ទះស៊ីបាយរួចហើយ ប្រាប់កូនប្រសាថា"ទៅផ្ទះចុះព្រឹកសឹមមកវិញ"។ ដល់យប់កូនប្រសាមកលបស្តាប់តាយាយគិតគ្នាទៀត។

លុះដល់យប់តាយាយចូលដេក តាប្រាប់យាយពីរឿងដែលកូនប្រសាធ្វើសព្វគ្រប់ហើយ តាឲ្យយាយជួយគិតទៀត។ ដូនចាស់ប្រាប់ថា"ពីមុនវាធ្វើឆ្កែ តាឯងធ្វើម្ចាស់ វាធ្វើបាបតាឯងបាន ដូច្នេះព្រឹកនេះតាឯងឲ្យវាធ្វើម្ចាស់ តាឯងធ្វើឆ្កែវិញ"។ តាយាយគិតគ្នាហើយដេកទៅ។ ចៅនោះលបស្តាប់បានការហើយ ក៏ដេកឯផ្ទះធ្វើវាហី។

ព្រឹកឡើងចៅនោះទៅបំរើឪពុកក្មេកម្តាយក្មេកទៀត។ តាយាយឲ្យកូនក្រមុំលើកបាយមកឲ្យស៊ីៗរួចហើយក៏តាប្រាប់ថា"ពីម្សិលមិញឯងធ្វើឆ្កែ ថ្ងៃនេះឯងធ្វើម្ចាស់អញៗធ្វើឆ្កែវិញ"។ ចៅនោះឆ្លើយបាទ ហើយពុនបាយទឹកទៅ ឯតាវារធ្វើឆ្កែបោលតាមក្រោយ។ លុះហួសពីផ្ទះបន្តិចវាខំដើរលឿន កុំឲ្យឪពុកក្មេកវាបោលទាន់។

តាបោលពុំទាន់ត្បិតខ្លួនចាស់ដើរត្រុកៗតាមក្រោយវា ក៏វាបែរមកថា"ឆ្កែអីស៊ីតែបាយបង្អស់ទៅមុខមិនទៅដើរតែក្រោយម្ចាស់ រកអណ្តើកម្តេចបាន?"ថាហើយវាយឆ្កែឱ្យបោលទៅមុខ។ តាបោលក្នុងស្មៅមិនរួចចេះតែដើរតាមក្រោយអណ្តើកក៏រកមិនបាន កូនប្រសាវាយស្ទើរស្លាប់ ហត់ស្ទើរដាច់ខ្យល់ តែពុំហ៊ានស្តីព្រោះខ្មាសកូនប្រសា។

លុះទៅឆ្ងាយដល់ថ្ងៃត្រង់ វាស្រាយបាយស៊ីហើយវាថា"ឆ្កែអីរកអណ្តើកមិនបានដើរតែក្រោយមនុស្ស ស៊ីតែបាយបង្អស់ " ហើយវាមិនឲ្យបាយស៊ី វាឲ្យតែឆ្អឹងឆ្អែងអង្កៀមក៏មិនបែក ត្បិតគ្មានធ្មេញ ឃ្លានណាស់អង្គុយតែមើលមុខវា ទាល់តែវាស៊ីអស់វាវាយមួយព្រនង់ទៀត វាថា"ណ្ហើយទៅផ្ទះចុះបើមិនផេះទេ ឆ្កែអីឆ្អែងយ៉ាងហ្នឹង" ហើយវាឡើងដើរវិលទៅផ្ទះវិញ។

តាចាស់ហត់ណាស់វារមិនរួច ឡើងដើរទៅតាមក្រោយ ថៅកម្លោះទៅដល់ផ្ទះប្រាប់ម្តាយក្មេកថា"ម៉ែ! រកអណ្តើកមិនបានទេព្រោះឆ្កែមិនស្ទាក់"។

តាចាស់ខឹងណាស់ប្រាប់កូនប្រសាថា"ឯងទៅផ្ទះចុះព្រឹកសឹមមកវិញ"។ ចៅនោះក៏លាទៅ ដល់យប់មកពួនលបស្តាប់ក្រោមផ្ទះទៀត។

លុះដល់យប់តាយាយចូលដេក តានិយាយប្រាប់យាយពីរឿងកូនប្រសាធ្វើបាបហើយបង្អត់ទាំងបាយផង។ ដូនថា"ណ្ហើយឲ្យកូនទៅវាទៅ ផ្តាច់វាមិនបានទេ អានេះ

មានប្រាជ្ញាណាស់ ឯងគិតអីវាដឹងមុនទាំងអស់ វាធ្វើបាបស្ទើរតែនឹងស្លាប់ ម្ដេចក៏មិនរៀង"។ តាចាស់ឆ្លើយថា "នឹងឲ្យទៅវា មើលទៅរូបរាងមិនសមនឹងកូនយើងសោះ ប៉ុន្តែយើងធ្វើកលឲ្យវាខឹង ឲ្យវាជេរម្ដាយ វាមិនជេរ ដូច្នេះដូនជួយគិតអញម្ដងទៀត បើវាធ្វើតាមមិនបាន សឹមផ្ដាច់វា"។ ដូនចាស់ថា "អើ! ឥឡូវនេះមានតែពេលមាន់រងាវឡើង តាឯងលប់មុខស៊ីស្លា ហូបបាយ ហើយចូលទៅក្នុងការុងមួយ ការុងមួយទៀតច្រកអង្ករ បើព្រឹកឡើងវាមកខ្ញុំប្រាប់ថា តាឯងទៅផ្សាទិញអីវ៉ាន់ហើយខ្ញុំប្រាប់វាឱ្យរែកទៅ ទៅឲ្យទាន់វេលាស៊ីបាយព្រឹក ត្បិតផ្លូវទៅផ្សារក៏ឆ្ងាយដែរ បើវារែកទៅមិនទាន់ មកវិញផ្ដាច់វាយ៉ាងងាយ មួយទៀតដល់ពាក់កណ្ដាលផ្លូវវាធ្ងន់ វាប្រហែលវាឃើញថា ស្ងាត់ហើយវាជេរមិនខាន"។ តាចាស់និងយាយគិតគ្នាហើយដេកទៅ។ ឯកូនប្រសាលបស្ដាប់នៅក្រោមផ្ទះ ដឹងការណ៍ហើយក៏ទៅដេកឯផ្ទះ។

លុះព្រឹកឡើងចៅនោះរៀបខ្លួន ដើរចេញទៅបំរើឪពុកក្មេកទៀត ដល់ហើយម្ដាយឲ្យកូនក្រមុំលើកបាយមកឲ្យចៅនោះស៊ីទៀត ស៊ីហើយក៏ប្រគល់អំរែកឲ្យកូនប្រសារែកទៅតាមឪពុកក្មេកឯផ្សារ ដូចគិតគ្នាពីល្ងាចនោះ។ ចៅនោះរែកដើរទៅហើយគិតថា "ម្ដងនេះអញធ្វើឲ្យឪពុកក្មេកអញនេះ ឱ្យកូនមកអញ កុំឲ្យរកកលធ្វើបញ្ឆោតអញក្រោយទៀត" ហើយគិតតែរែកទៅដល់ពាក់កណ្ដាលផ្លូវ ដាក់អម្រែកចុះ ហើយថាការុងនេះចងមាត់មិនជាប់ ក៏យកខ្សែចងថែមទៀត លុះរែកដើរទៅដល់កណ្ដាលផ្លូវមានព្រែកមានស្ពាន ក៏ដាក់អម្រែកលើស្ពានត្រង់ចុងក្ដារ នៅតែបន្តិចនឹងធ្លាក់ពីស្ពានហើយថា "អញអើយថ្ងៃណាស់ហើយ ម្ល៉េះសមឪជេរមិនខាន អម្រែកធ្ងន់រែកម្ដេចឲ្យទាន់ ល្ហើយ! ឪជេរក៏ជេរចុះ អញដាក់នៅលើនេះទៅវាលសិន រួចសឹមទៅទៀត" និយាយបណ្ដើរដើរទៅបណ្ដើរ។ មួយស្របក់ក៏កាន់ឈើមួយធំ ដើរមកពីនាយបុកក្ដារស្ពានឮគ្រាំៗ ធ្វើជាដើរឆ្លងស្ពានហើយស្រែកថា "នរណាដាក់អំរែកនៅលើស្ពាន ដើរអញវាជាន់ខូចអស់ហើយ យកចេញឲ្យឆាប់"។ ស្រែកហើយបុកក្ដារដើរគ្រាំៗចូលមក។

ឯតាចាស់នៅក្នុងការុងគិតស្មានថាជាដំរីមែនភ័យក្រែងជាន់ស្លាប់ក៏បម្រះជៀសផ្លូវដំរី ហួសពីក្ដារធ្លាក់ទៅក្នុងទឹកៗ ចូលការុងឈ្លក់ទឹកត្រដរញ័រទាំងការុងស្ទើរតែនឹងស្លាប់។ ឯកូនប្រសាឃើញដូច្នោះ ក៏ទុកឲ្យផឹកទឹកបន្តិចកុំឲ្យខូចទៀត ហើយធ្វើជាដើរមកពីវាលស្រែថា "នរណាហ៊ាន បរដំរី ឆាយអំរែកអញធ្លាក់ក្នុងទឹកទទឹកអង្ករអស់ ឪអញអើយ! ឪជេរថែម ទៀតហើយ ថ្ងៃក៏កាន់តែខ្ពស់ ហើយអង្ករក៏ទទឹកអស់ថែមទៀត"។ អ្នកកម្លោះឃើញឪក្មេកបម្រះញ័រក្នុងការុងក៏ថា "ឪមានត្រីមកបបេះផង ល្ហើយអញចុះទៅស្រង់ឡើងមកមើល" ថាហើយក៏លោតទៅស្រង់ឡើងមកមើលហើយថា "អើបើវាទទឹកនឹងស្រាយហាលថ្ងៃ ហើយរែកយកទៅ ឲ្យម៉ែធ្វើនំបញ្ចុកឲ្យឪ"។ ថាហើយស្រាយមើលឃើញតានៅក្នុងការុងក៏ថា "ឪឪអើយម្ដេចមិនស្រែកប្រាប់ខ្ញុំ កុំអីស្លាប់ទៅហើយ គេបរដំរីមកពីណា មិនដឹងគេឱ្យដំរីឆាយធ្លាក់ទៅក្នុងទឹក"។ តាឮហើយឡើងឈរ ដើរវិលមកផ្ទះវិញមិនមានស្ដីមួយម៉ាត់ ដល់ទៅផ្ទះអស់ចំណេះមិនហ៊ានគិតទៀត ក៏រៀបការកូនក្រមុំឱ្យទៅអ្នកកម្លោះនោះទៅ។

**និយាយយប់ផ្អប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក**